# កិច្ចព្រមព្រៀង

# រវាង

# រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

# និង

# រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

# ស្តីពី

# កិច្ចសហប្រតិបត្តិការបច្ចេកទេស

# ឆ្នាំ ២០១៩

# រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

# និង

# រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

ក្នុងស្មារតីនៃទំនាក់ទំនងមិត្តភាពរវាងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងព្រះរាជាណាចក្រកម្ពុជា

ក្នុងគោលបំណងពង្រឹងទំនាក់ទំនងមិត្តភាព តាមរយៈកិច្ចសហប្រតិបត្តិការបច្ចេកទេស ក្នុងស្មារតីភាពជាដៃគូ

ដោយយល់ថា ការថែរក្សាទំនាក់ទំនងនេះ គឺជាមូលដ្ឋានគ្រឹះនៃកិច្ចព្រមព្រៀងនេះ

ក្នុងគោលបំណងរួមចំណែកការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា

យោងកំណត់ហេតុនៃកិច្ចចរចាអន្តររដ្ឋាភិបាល ដែលបានប្រព្រឹត្តទៅនៅទីក្រុងប៉ៃកឡាំង នាថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៩

បានព្រមព្រៀងដូចខាងក្រោម÷

## មាត្រា ១

(១) យោងតាមកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស ដែលត្រូវបានចុះហត្ថលេខាកាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៤ រវាងរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា, គម្រោងដូចខាងក្រោម នឹងត្រូវបានទទួលការគាំទ្រ ប្រសិនបើពិនិត្យឃើញថា គម្រោងទាំងនេះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ទទួលបានការគាំទ្រ ÷

១- ការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ

២- ការគាំពារសុខភាពសង្គម

៣- ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន

៤- មូលនិធិសម្រាប់ការសិក្សា និងអ្នកជំនាញ ។

(២) សម្រាប់គម្រោងដែលមានចែងក្នុងកថាខណ្ឌ (១) ខាងលើ រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់នឹងផ្តល់ហិរញ្ញប្បទានឥតសំណងសរុប ចំនួន ១៣.៥០០.០០០ អឺរ៉ូ (ដប់បីលានប្រាំរយពាន់អឺរ៉ូ) ក្នុងទម្រង់ជាការផ្តល់បុគ្គលិក, ធាតុចូល និងការផ្តល់ជាហិរញ្ញប្បទាន នៅពេលមានភាពចាំបាច់ ។ ទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេស (GIZ) ត្រូវទទួលបន្ទុកអនុវត្តគម្រោងដែលមានចែងក្នុងកថាខណ្ឌ (១) ខាងលើ ។

(៣) រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវធានាថា គម្រោងដូចមានចែងក្នុងកថាខណ្ឌ (១) ត្រូវមានខ្ទង់ថវិកាផ្ទាល់ ដើម្បីធានាភាពរលូនក្នុងការអនុវត្ត និងត្រូវធានាថា ស្ថាប័នដែលទទួលបន្ទុកអនុវត្តគម្រោង នឹងផ្តល់ការគាំទ្រចាំបាច់នានាសម្រាប់គម្រោងដែលមានចែងក្នុងកថាខណ្ឌ (១) ខាងលើ ។

(៤) ការសន្យាសម្រាប់គម្រោងដែលមានចែងក្នុងកថាខណ្ឌ (១) ខាងលើ និងការសន្យាផ្តល់ហិរញ្ញប្បទានសម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេសដែលមានចែងក្នុងកថាខណ្ឌ (២) ខាងលើ នឹងត្រូវផុតសុពលភាព ដោយមិនអាចធ្វើការជំនួសដោយគម្រោងផ្សេងបានឡើយ ប្រសិនបើកិច្ចព្រមព្រៀងអនុវត្តគម្រោង និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ដូចមានចែងក្នុងមាត្រា ២ នៃកិច្ចព្រមព្រៀងនេះ ពុំត្រូវបានចុះហត្ថលេខា ក្នុងអំឡុងពេល ៤ឆ្នាំ បន្ទាប់ពីឆ្នាំដែលការសន្យាត្រូវបានប្រកាស ។ កាលបរិច្ឆេទផុតសុពលភាពនៃការសន្យានេះ គឺថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ។

## មាត្រា ២

ខ្លឹមសារលម្អិតនៃគម្រោងដែលមានចែងក្នុងមាត្រា ១ (១) នៃកិច្ចព្រមព្រៀងនេះ និងការផ្តល់ការគាំទ្រ ព្រមទាំងកាតព្វកិច្ចនានា នឹងត្រូវកំណត់ក្នុងកិច្ចព្រមព្រៀងអនុវត្តគម្រោងនីមួយៗ និងកិច្ចព្រមព្រៀងហិរញ្ញប្បទានដោយឡែកក្នុងករណីចាំបាច់ ដែលនឹងត្រូវចុះហត្ថលេខារវាងស្ថាប័នទទួលបន្ទុកអនុវត្ត ឬរវាងស្ថាប័នដែលនឹងត្រូវបានចាត់តាំងឱ្យអនុវត្តគម្រោង ដូចមានចែងក្នុងមាត្រា ១ (២) និង ១ (៣) នៃកិច្ចព្រមព្រៀងនេះ ។ កិច្ចព្រមព្រៀងអនុវត្តគម្រោង និងកិច្ចព្រមព្រៀងហិរញ្ញប្បទានទាំងនេះ នឹងត្រូវអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនានារបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ។

## មាត្រា ៣

(១) រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវលើកលែងពន្ធនាំចូល និងពន្ធនាំចេញលើសម្ភារ, យានយន្ត, ផលិតផល, បរិក្ខារ និងគ្រឿងបន្លាស់ ដល់រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ក៏ដូចជាទទួលបន្ទុកបង់ជំនួសនូវថ្លៃអាជ្ញាប័ណ្ណ, ថ្លៃឈ្នួលចូលចត, ថ្លៃឈ្នួលឃ្លាំង និងថ្លៃសេវាសាធារណៈដទៃទៀត សម្រាប់អនុវត្តគម្រោងដែលមានចែងក្នុងមាត្រា ១ (១) នៃកិច្ចព្រមព្រៀងនេះ ហើយត្រូវធានាមិនឱ្យយឺតយ៉ាវក្នុងការបញ្ចេញទំនិញទាំងអស់នេះ ។

(២) រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តល់ជូនភ្នាក់ងារអនុវត្តគម្រោង នូវការលើកលែងពន្ធ និងអាករផ្ទាល់ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលពាក់ព័ន្ធនឹងការចុះហត្ថលេខា និងការអនុវត្តកិច្ចព្រមព្រៀងអនុវត្តគម្រោង និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ដូចមានចែងក្នុងមាត្រា ២ នៃកិច្ចព្រមព្រៀងនេះ ។

(៣) តាមសំណើរបស់ភ្នាក់ងារអនុវត្តអាល្លឺម៉ង់ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវទូទាត់សងវិញ នូវអាករលើតម្លៃបន្ថែម ឬពន្ធមិនចំពោះផ្សេងៗ លើផលិតផល និងសេវា ដែលបានធ្វើលទ្ធកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ដែលពាក់ព័ន្ធនឹងការចុះហត្ថលេខា និងការអនុវត្តកិច្ចព្រមព្រៀងអនុវត្តគម្រោង និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ដូច មានចែងក្នុងមាត្រា២ នៃកិច្ចព្រមព្រៀងនេះ ។ ទន្ទឹមនឹងនេះ តាមសំណើរបស់ភ្នាក់ងារអនុវត្តអាល្លឺម៉ង់ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានឹងត្រូវបង់ពន្ធលើការប្រើប្រាស់ ។

## មាត្រា ៤

កិច្ចព្រមព្រៀងនេះ មានវិសាលភាពគ្រប់ដណ្ដប់លើគម្រោងដែលមានចែងក្នុងមាត្រា ១ (១) ខាងលើ ក៏ដូចជាវិធានការសម្រាប់បន្តអនុវត្តគម្រោងដែលមានឈ្មោះដូចគ្នា ក្នុងករណីរដ្ឋាភិបាលទាំងពីរមានបំណងបន្តផ្តល់ការគាំទ្រដល់គម្រោងមួយ ឬគម្រោងជាច្រើន ។ ការសន្យាផ្តល់ការគាំទ្ររបស់រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់លើវិធានការសម្រាប់បន្តអនុវត្តគម្រោងមួយ ឬគម្រោងជាច្រើន ដែលមានចែងក្នុងមាត្រា ១ (១) នៃកិច្ចព្រមព្រៀងនេះ នឹងត្រូវធ្វើឡើង តាមរយៈការផ្តល់ព័ត៌មានផ្លូវការពីរដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ដោយផ្អែកតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា ៥

ក្នុងគ្រប់ទិដ្ឋភាពដទៃទៀត បញ្ញត្តិទាំងឡាយក្នុងកិច្ចព្រមព្រៀងស្ដីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស ដែលត្រូវបានចុះហត្ថលេខារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ នាថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៤ ហើយដែលបានចែងក្នុងមាត្រា ១ (១) ខាងលើ នឹងត្រូវយកមកអនុវត្តចំពោះកិច្ចព្រមព្រៀងនេះ ។

## មាត្រា ៦

(១) កិច្ចព្រមព្រៀងនេះ នឹងត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

(២) កិច្ចព្រមព្រៀងនេះត្រូវចុះហត្ថលេខាសម្រាប់រយៈពេលគ្មានកំណត់ ។ ភាគីម្ខាងនៃកិច្ចព្រមព្រៀងអាចស្នើសុំបញ្ចប់ជាលាយលក្ខណ៍អក្សរ ដោយជូនដំណឹងជាមុនរយៈពេល ៦ ខែ ។

(៣) ភាគីនៃកិច្ចព្រមព្រៀង អាចឯកភាពលើការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងនេះបាន ។

(៤) រាល់វិវាទពាក់ព័ន្ធនឹងការបកស្រាយ និងការអនុវត្តកិច្ចព្រមព្រៀងនេះ នឹងត្រូវដោះស្រាយដោយមេត្រីភាពរវាងភាគីទាំងពីរ តាមរយៈការពិភាក្សា ឬការចរចា ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១ ខែ មិថុនា ឆ្នាំ២០២០ ជា ០២ ច្បាប់ដើម ជាភាសាអាល្លឺម៉ង់, ភាសាខ្មែរ និងភាសាអង់គ្លេស ។ អត្ថបទទាំង ៣ ភាសានេះ មានតម្លៃស្មើគ្នា ។ ក្នុងករណីមានការបកស្រាយមិនស្របគ្នារវាងអត្ថបទភាសាអាល្លឺម៉ង់ និងភាសាខ្មែរ នោះអត្ថបទភាសាអង់គ្លេសនឹងត្រូវទុកជាបានការ ។

| **តំណាង** | **តំណាង** |
| --- | --- |
| **រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា** | **រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់** |
| Sean B. Chin | |